ព្រឹត្តិបត្រព័ត៌មានអំពីផ្នែកបរិយាបន្នពិការភាព

ផ្នែកបរិយាបន្នពិការភាព ACCESS 2

កម្មវិធីសហប្រតិបត្តិការអូស្ត្រាលី-កម្ពុជា ដើម្បីការផ្តល់សេវាប្រកបដោយនិរន្តរភាព និងសមធម៌ - ដំណាក់កាលទី២

ការពង្រឹងបរិយាបន្នពិការភាពនៅកម្ពុជា

កម្មវិធី ACCESS 2 កំពុងពង្រឹងប្រព័ន្ធបរិយាបន្នពិការភាពនៅកម្ពុជា ដើម្បីឱ្យជនមានពិការភាពអាចទទួលបានសេវាកិច្ចគាំពារសង្គម និងឱកាសក្នុងការចូលរួមក្នុងជីវភាពសង្គមកាន់តែប្រសើរ។ តាមរយៈកិច្ចសហការជាមួយរាជរដ្ឋាភិបាល រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការជនមានពិការភាព កម្មវិធីនេះគាំទ្រដល់ការកំណត់អត្តសញ្ញាណកម្មពិការភាពតាមរយៈប្រព័ន្ធគ្រប់គ្រងទិន្នន័យពិការភាព (DMIS) កិច្ចគាំពារសង្គម ការរៀបចំផែនការ និងថវិកាប្រកបដោយបរិយាបន្នពិការភាព ការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព (NDSP) ឆ្នាំ២០២៤-២០២៨ និងការពង្រឹងការចូលរួមរបស់អង្គការតំណាងជនមានពិការភាព (OPDs)។ កិច្ចខិតខំប្រឹងប្រែងទាំងនេះរួមចំណែកដល់ការពង្រឹងអភិបាលកិច្ចប្រកបដោយបរិយាបន្ន ការលើកកម្ពស់លទ្ធភាពទទួលបានសេវា និងកិច្ចគាំពារសង្គម និងបង្កើនការចូលរួមក្នុងការសម្រេចចិត្តដែលជះឥទ្ធិពលដល់ជីវភាពរបស់ប្រជាពលរដ្ឋ។

និដ្ឋភាពរួមផ្នែកបរិយាបន្នពិការភាព

- បានចុះឈ្មោះជនមានពិការភាពចំនួនជាង ៣៧0.000នាក់ នៅក្នុងប្រព័ន្ធ DMIS
- ជនមានពិការភាពចំនួនជាង ២៨0.000 នាក់ ទទួលបានបណ្ណសម្គាល់ជនមានពិការភាព
- ជនមានពិការភាពចំនួនជាង ៦៧.000 នាក់ បានបញ្ចូលក្នុងកម្មវិធីកញ្ចប់គ្រួសារ
- បានពង្រឹងសមត្ថភាពអង្គការតំណាងជនមានពិការភាពបានចំនួន៤0នាក់
- ឃុំ សង្កាត់ចំនួន២៤0 បានតែងតាំងជនមានពិការភាពជាសមាជិក គ.ក.ន.ក.
- បានគាំទ្រដល់ការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពលើកទី៣
- ប្រព័ន្ធ DMIS * បានដំណើរការ និងបានធ្វើសមកាលកម្មជាមួយប្រព័ន្ធជាតិផ្សេងទៀត
- សេចក្តីព្រាងផែនការសមធម៌សុខភាពជនមានពិការភាព ឆ្នាំ ២0២6-២0៣៥

តើកម្មវិធី ACCESS 2 អនុវត្តសកម្មភាពអ្វីខ្លះ?

១ ពង្រឹងគោលនយោបាយ និងប្រព័ន្ធ

គាំទ្រយុទ្ធសាស្ត្រពាក់ព័ន្ធនឹងពិការភាព ក្របខណ្ឌសម្រាប់ការរៀបចំផែនការ និងថវិកាប្រកបដោយបរិយាបន្ន និងគោលនយោបាយឆ្លើយតបនឹងពិការភាព។

២ ពង្រីកលទ្ធភាពទទួលបានកិច្ចគាំពារសង្គម

ធ្វើឱ្យប្រសើរឡើងនូវការកំណត់អត្តសញ្ញាណកម្មពិការភាព និងពង្រឹងការផ្សារភ្ជាប់ជាមួយនឹងកម្មវិធី និងសេវាកិច្ចគាំពារសង្គមរបស់រាជរដ្ឋាភិបាល។

៣ ពង្រឹងអង្គការតំណាងជនមានពិការភាព (OPDs)

គាំទ្រ OPDs ក្នុងការស្វែងរកមតិគាំទ្រ ដើម្បីលើកកម្ពស់សិទ្ធិជនមានពិការភាព និងចូលរួមក្នុងគោលនយោបាយ ការរៀបចំផែនការ និងអភិបាលកិច្ច។

៤ កសាងសហគមន៍ប្រកបដោយបរិយាបន្ន

លើកកម្ពស់កិច្ចសហការរវាងសហគមន៍ អាជ្ញាធរមូលដ្ឋាន អ្នកផ្តល់សេវា និង OPDs។



សកម្មភាពលេចធ្លោរបស់ផ្នែកពិការភាព

កិច្ចប្រជុំក្រុមការងារបរិយាបន្នពិការភាព

កិច្ចប្រជុំផ្នែកបរិយាបន្នពិការភាពប្រចាំឆមាស បានប្រមូលផ្តុំដៃគូរដ្ឋាភិបាល ដៃគូអនុវត្តជាយុទ្ធសាស្ត្រផ្នែកបរិយាបន្នពិការភាព OPDs និងភាគីពាក់ព័ន្ធ ដើម្បីពិនិត្យមើលវឌ្ឍនភាព ចែករំលែកមេរៀន បទពិសោធន៍ និងកំណត់អាទិភាពដើម្បីលើកកម្ពស់បរិយាបន្នពិការភាព។ កិច្ចពិភាក្សាផ្តោតលើជាសុកវត្ថុ កិច្ចគាំពារសង្គម និងអភិបាលកិច្ចប្រកបដោយបរិយាបន្ន និងលទ្ធផលកាន់តែប្រសើរសម្រាប់ជនមានពិការភាព។

ផ្នែកបរិយាបន្នពិការភាព

ដៃគូ សកម្មភាព និងលទ្ធផល

តើយើងធ្វើការជាមួយអ្នកណាខ្លះ?

ភាពដៃគូជាមួយរាជរដ្ឋាភិបាលកម្ពុជា

- ក្រុមប្រឹក្សាសកម្មភាពជនពិការ (DAC & PDAC)
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (MoSVY)
- មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត (PoSVY)
- រដ្ឋបាលថ្នាក់ក្រោមជាតិ (SNA)

ដៃគូអនុវត្តជាយុទ្ធសាស្ត្រ

- អង្គការ UNICEF
- អង្គការសកម្មភាពប្រជាជនដើម្បីការអភិវឌ្ឍប្រកបបរិយាបន្ន (PAfID)
- អង្គការជនពិការកម្ពុជា (CDPO)

សកម្មភាពចម្បងៗ

១ គោលនយោបាយ និងប្រព័ន្ធរឹងមាំជាងមុន

បានគាំទ្រដល់ការអនុវត្ត NDSP3 ការដាក់ឱ្យអនុវត្តសារាចរលេខ ០០៧ ការប្តេជ្ញាចិត្ត «១៥% សម្រាប់ ១៥% » និងការតាក់តែងសេចក្តីព្រាងផែនការយុទ្ធសាស្ត្រ និងគោលនយោបាយសមធម៌សុខភាពពិការភាព។

២ ការពង្រីកកិច្ចគាំពារសង្គម

បានចុះបញ្ជីជនមានពិការភាពជាង ៣៧០.០០០នាក់ ក្នុងនោះជនមានពិការភាពជាងជាង ៣៦០.០០០ នាក់ ត្រូវបានអនុម័តក្នុងប្រព័ន្ធ DMIS។ ជនមានពិការភាពចំនួន ២៨០.០០០នាក់ ទទួលបានបណ្ណសម្គាល់ជនមានពិការភាព ហើយជាង ៦៧.០០០ នាក់ បានបញ្ចូលក្នុងកម្មវិធីកញ្ចប់គ្រួសារ។

៣ ការពង្រឹងតំណាងរបស់ OPDs

OPDs ចំនួន៤០ ត្រូវបានពង្រឹងសមត្ថភាពតាមរយៈការផ្តល់ជំនួយហិរញ្ញវត្ថុ និងការកសាងសមត្ថភាព ដែលបានបង្កើនការតំណាង និងការចូលរួមរបស់ពួកគេនៅក្នុងដំណើរការអភិបាលកិច្ច។

៤ សហគមន៍ និងសេវាប្រកបដោយបរិយាបន្ន

ឃុំ សង្កាត់ចំនួន២៤០ បានតែងតាំងជនមានពិការភាពជាសមាជិក គ.ក.ន.ក. ព្រមទាំងពង្រឹងការសម្របសម្រួលជាមួយអាជ្ញាធរ និងអ្នកផ្តល់សេវាឱ្យកាន់តែមានប្រសិទ្ធភាព។

បរិយាបន្នពិការភាពក្នុងសកម្មភាពអនុវត្តជាក់ស្តែង







អគារ ANINA ជាន់ទី៣ ផ្លូវ២៧១ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

info@access2cambodia.org www.access2cambodia.org

ACCESS 2 ត្រូវបានគាំទ្រដោយរដ្ឋាភិបាលអូស្ត្រាលី និងគ្រប់គ្រងដោយ Abt Global។